# គណបក្ស សិទ្ធិមនុស្ស

HUMAN RIGHTS PARTY

បំរើ ការពារ កសាង

**កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ**

*ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍* *ថ្ងៃសុក្រ ទី០១ ខែឧសភា ឆ្នាំ២០០៩* *ព្រឹត្តិប័ត្រលេខ៨២ ឆ្នាំទី២*



| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| -តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស និងគណបក្សសមរង្ស៊ីចូលរួមដង្ហែក្បួន ទិវាពលកម្មអន្តរជាតិខួបលើកទី១២៣ | ១ |
| -ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សចុះសំណេះសំណាលជាមួយសកម្មជន និងអ្នកគាំទ្រនៅខេត្តតាកែវ | ២ |
| -ឯកឧត្តម គឹម សុខា អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាមចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋនៅមូលដ្ឋាន | ៣ |
| -សេចក្តីជូនដំណឹង | ៤ |


## តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស និងគណបក្សសមរង្ស៊ីចូលរួមដង្ហែក្បួន ទិវាពលកម្មអន្តរជាតិខួបលើកទី១២៣

នៅថ្ងៃនេះមានកម្មករប្រមាណជាង៣០០០នាក់ បានចូលរួមដង្ហែក្បួន ០១ ឧសភា ទិវាពលកម្មអន្តរជាតិ ខួបលើកទី ១២៣ ដែលពិធីនេះប្រារព្ធធ្វើនៅមុខរដ្ឋសភាចាស់ ហើយដង្ហែរទៅកាន់ជ្រុងវត្តលង្ការាជធានីភ្នំពេញ ជាកន្លែងដែលគេបាញ់សំលាប់ លោក **ជា វិជ្ជា** ។

ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ដែលនៅខេត្តពោធិសាត់បានប្រាប់ថានៅពិធីដង្ហែរក្បួន០១ឧសភា ជាការទាមទារឱ្យរដ្ឋាភិបាលបង្កើតតុលាការការងារ ឱ្យបានឆាប់រហ័ស និងឱ្យរដ្ឋាភិបាលយល់អំពីទុក្ខលំបាក របស់គ្រូបង្រៀនដែលខិតខំធ្វើការ ប៉ុន្តែទទួលបាននូវប្រាក់បៀវត្សរ៍មិនសមនឹងកំលាំងពលកម្ម ។

ប្រធានសមាគមរូបនេះបានបន្តទៀតថា សូមឱ្យរដ្ឋាភិបាលលុបបំបាត់នូវការរើសអើង ការមើលងាយ មើលថោក ហើយក្នុងនោះ ទាំងប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យនៅខេត្តពោធិសាត់ និងកម្មករទាំងអស់ទាមទារឱ្យមានតុលាការការងារផងដែរ ។ ប្រសិនបើមានតុលាការការងារនឹងជួយរកយុត្តិធមិខណៈពេលមានការរំលោភសិទ្ធិរវាងស្ថាប័ន នឹងក្រុមគ្រូបង្រៀន ។

លោក **អាត់ ធន** ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាហៅថា **ស៊ីកាឌូ** បានថ្លែងប្រាប់ ក្រុមអ្នកសារពតិមានជាតិ និងអន្តរជាតិនៅមុនពិធីដង្ហែក្បួ ចាប់ផ្តើមបន្ទិចថា យើងប្រារព្ធពិធីនេះឡើងដើម្បីអបអរសាទរទិវាពលកម្មអន្តរជាតិ ថ្ងៃ០១ ឧសភា ក្នុងនោះយើងក៏បានដាក់ញ្ញាតិ និងសំណើសុំទៅរដ្ឋសភា និងរដ្ឋាភិបាលទាក់ទងនឹងការគោរពសិទ្ធិសេរីភាព និងផលប្រយោជន៏របស់កម្មករ ។ ដោយលោកមើលឃើញថា មិនទាន់ឈានទៅដល់ស្តង់ដារនោះនៅឡើយទេ។

លោក **អាត់ ធន** បានថ្លែងនៅមុខហ្វូងកម្មកររាប់ពាន់នាក់បន្តថា លោកស្នើដល់រដ្ឋាភិបាលសូមឱ្យបង្កើតតុលាការការងារសំរាប់ដោះស្រាយវិវាទការងារឱ្យមានប្រសិទ្ធិភាព។ ម្យ៉ាងទៀតរដ្ឋាភិបាលត្រូវតែរកទីផ្សារការងារ រក្សាទីផ្សារការងារបច្ចុប្បន្នភាពនៅបានព្រមទាំងឱ្យមានលក្ខខណ្ឌការងារល្អ ។

លោក **អាត់ ធន** បានគូសបញ្ជាក់ថា នៅឆ្នាំ២០០៨កន្លងនេះមានរោងចក្រចំនួន១០បានបញ្ឈប់ថ្នាក់ដឹកនាំសហជីពរបស់ស៊ីខៅឌូ ចំនួន១១៥នាក់។ រហូតមកដល់ពេលនេះមានកម្មករជាង៦ម៉ឺននាក់អត់ការងារធ្វើ និងរោងចក្រជាង១០០ បានបិទទ្វារដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក ។

លោក **ជា មុនី** ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ជាក់ថា កម្មករដែលបានចូលរួមក្នុងថ្ងៃ០១ឧសភា ទិវាពលកម្មអន្តរជាតិ គឺកម្មករទាំងអស់ចង់សំដែងនូវទុក្ខកង្វល់ដែលរដ្ឋាភិបាលមិនបានគិតគូរដល់ពួកគេ ។ កម្មករជាច្រើនម៉ឺននាក់បាត់បង់ការងារហើយកម្មករចង់ឱ្យមានតុលាការការងារនៅកម្ពុជា មានច្បាប់ការងាររួចហើយប៉ុន្តែតុលាការការងារមិនទាន់មាន ។ ដូច្នេះបានជាមានកម្មករមួយចំនួនជាប់គុក គេបាញ់សំលាប់ និងមួយចំនួនផ្សេងទៀតត្រូវបានគេប្តឹងទារជំងឺចិត្តរហូតដល់ ១៦ម៉ឺនដុល្លារ ។ លោក **ជា មុនី** បានបន្ថែមថា លោកស្នើឱ្យថៅកែរោងចក្រមានប្រាក់តំកល់ទុកនៅក្នុងធនាគារជាមួយគ្នានេះ ប្រធានសហជីពសេរីកម្មករបានបញ្ជាក់ថា វិស័យអត្ថិភាពជាងគេ គឺវិស័យកាត់ដេរ ។ ប្រសិនបើគិតតែអំពីអំពើពុករលួយ និងមិនគិតអំពីប្រយោជន៍កម្មករ វិស័យកាត់ដេរនឹងដួលរលំ ។

លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស និងលោក **សម រង្ស៊ី** ប្រធានគណបក្ស សម រង្ស៊ី ដែលមានវត្តមាននៅមុខរដ្ឋសភាក្នុងនោះ លោក **កឹម សុខា** បានថ្លែងទៅកាន់កម្មកររាប់ពាន់នាក់ថា សូមឱ្យរដ្ឋាភិបាលកម្ពុជាការពារនូវតំលៃស្ត្រីខ្មែរ ជាពិសេសកម្មការនីដែលមានភាពទន់ខ្សោយក្នុងកំលាំងពលកម្មឱ្យបានទទួលនូវផលប្រយោជន៍ ស្មើគ្នាក្នុងសង្គមជាពិសេសក្នុងការការពារសុខភាព ។

លោក **កឹម សុខា** បានមានប្រសាសន៍ទៀតថា សូមឱ្យរដ្ឋាភិបាលលើកស្ទួយជីវភាពកម្មករ កុំលើកស្ទួយតែជីវភាពថៅកែ ។

នៅក្នុងក្បួននោះផងដែរ គេសង្កេតឃើញថា កម្មករលើកបដាខ្លះបានសរសេរថាសិទ្ធិកម្មករជាសិទ្ធិមនុស្ស បញ្ឈប់ការរើសអើងចំពោះសិទ្ធិសេរីភាពសមាគម និងសហជីពលុបបំបាត់ការប្រើកិច្ចសន្យារយៈពេលខ្លី បញ្ឈប់ការគំរាមកំហែងលើថ្នាក់ដឹកនាំសហជីព និងសមាគម និងការទាមទារឱ្យមានប្រាក់ខែសមរម្យសំរាប់កម្មករ គឺ១២០ដុល្លារក្នុងមួយខែ ។

## ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស ចុះសំណេះសំណាលជាមួយសកម្មជន និងអ្នកគាំទ្រនៅខេត្តតាកែវ

កិច្ចសំណេះសំណាលរបស់ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សនៅថ្ងៃនេះប្រារព្ធធ្វើនៅភូមិដើមផ្ទៀក ឃុំព្រៃស្លឹក ស្រុកទ្រាំងខេត្តតាកែវ ក្រោមអធិបតីភាពលោក **កឹម សុខា** សមាជិករដ្ឋសភារបស់គណបក្សសិទ្ធិមនុស្ស និងលោក **ប៉ែន សុវណ្ណ** ប្រធានគណៈកម្មាធិការវិន័យគណបក្សសិទ្ធិមនុស្ស ។

ថ្លែងទៅកាន់សកម្មជនអ្នកគាំទ្រគណបក្សសិទ្ធិមនុស្ស លោក **ប៉ែន សុវណ្ណ** ប្រធានគណៈកម្មាធិការវិន័យគណបក្សសិទ្ធិមនុស្ស ដែលលោកមានវត្តមាននៅក្នុងពិធីសំណេះសំណាលនោះដែរបានមានប្រសាសន៍ថា សព្វថ្ងៃនេះនៅខេត្តតាកែវ មានជនជាតិយួនចូលមកលក់ដូរបន្លែ បង្គារ ផ្លែឈើ សំលៀកបំពាក់ធ្វើសក់ កាត់សក់ វត់តាក់ស៊ី ធ្វើឱ្យប៉ះពាល់ដល់អាជីវកម្មខ្មែរយើង ។ កាលពីមុនយួរមិនហ៊ានចូលទឹកដីខេត្តតាកែវលក់ដូរ

ដូច្នេះទេ ប៉ុន្តែឥឡូវមានច្រើនដោយសារអាជ្ញាធរមិនចាត់វិធានការ ។

លោក **ប៉ែន សុវណ្ណ** បានសង្កត់ធ្ងន់ថា យើងជាខ្មែរមិនមែនមានគំនិតចង្អៀតចង្អល់ជាតិនិយមនោះទេ ។ ប៉ុន្តែយើងទាមទារឱ្យប្រទេសជិតខាងគោរពបូរណភាពទឹកដី អធិបតេយ្យ និងមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង ។

លោក **កឹម សុខា** ប្រធានគណបក្សបានថ្លែងទៅកាន់សកម្មជនថា ពាក្យថាគោរពច្បាប់ ហៅថានីតិរដ្ឋនោះគឺជាការខុសឆ្គង ។ លោក **កឹម សុខា** បានលើកឧទាហរណ៍បញ្ជាក់ថា នៅសម័យសង្គ្រាមលោកលើកទី១ ដែលប្រទេសអាឡឺម៉ង់ អ៊ីត្លែរ មេដឹកនាំអាឡឺម៉ង់លោកបានឱ្យសភាជាតិធ្វើច្បាប់មួយដើម្បីសំរាប់ជនជ្វីស ជាជនជាតិភាគតិចនៅអាឡឺម៉ង់ ។ ក្រោយមកមន្ត្រីរបស់អ៊ីត្លែរក៏សំលាប់ជនជាតិជ្វីស ដោយសារគោរពតាមច្បាប់ ។ អតីតសមាជិកព្រឹទ្ធសភា លោក **កឹម សុខា** បានបញ្ជាក់ថា ច្បាប់របៀបអ៊ីត្លែមិនមែនជាច្បាប់ប្រជាធិបតេយ្យនោះទេ ។

លោកថា កាលពីថ្ងៃទី២៩ ខែឧសភា សមាជិកសភាគណបក្សសិទ្ធិមនុស្ស និងគណបក្សសមរង្ស៊ី បានដើរចេញពីសភា ដោយសារហេតុផលថា សមាជិកសភា គណបក្សសមរង្ស៊ីស្នើសុំកែឃ្លោងឃ្លាពាក្យពេចន៍ខ្លះ នៃសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារ និងលើកកំពស់សិទ្ធិជនពិការ ។ ប៉ុន្តែបទបញ្ជាផ្ទៃក្នុងតំរូវឱ្យធ្វើលិខិតស្នើសុំជាលាយលក្ខ័ណអក្សរ សុំមកសភាដើម្បីធ្វើវិសោធនកម្ម តែក៏ត្រូវបានសភាធ្វើការបដិសេធចោលមុនពេលមើលសេចក្តីព្រាងស្នើដោយគណបក្សប្រឆាំងទៅវិញ ។

សកម្មជនគណបក្សសិទ្ធិមនុស្សនៅឃុំអង្គកែវ ស្រុកទ្រាំងបាននិយាយថា អាជ្ញាធរភូមិឃុំអង្គកែវ មានការរើសអើងប្រជាពលរដ្ឋដូចជា រូបគាត់ជាតឹកតាងស្រាប់នៅពេលពឹងពាក់មេភូមិ ឱ្យស៊ីញ៉េលើលិខិតស្នាមខ្ចីលុយពីអង្គការ អង្គការគេមិនយល់ព្រមឱ្យខ្ចី ប៉ុន្តែមេភូមិរកលេសគ្រប់មធ្យោបាយបន្ទុចបង្អាក់មិនស៊ីញ៉េលើលិខិតស្នាម ។ នេះមិនមែនតែរូបគាត់មួយប៉ុណ្ណោះទេ សូម្បីអ្នកផ្សេងទៀតដែលមាននិន្នាការគាំទ្របក្សផ្សេងពីគណបក្សប្រជាជននោះ ក៏មេភូមិប្រកាន់ឬករាងក្រអឺតក្រទមផងដែរ ។

សកម្មជនរូបនោះបានបន្តថា អាជ្ញាធរប្រកាន់ឬកពាររើសអើងយ៉ាងនេះ ក្នុងន័យចង់បំបាក់ស្មារតីប្រជាពលរដ្ឋឱ្យខ្លបខ្លាចមិនឱ្យគាំទ្របក្សផ្សេង ។

តំណាងគណបក្សសិទ្ធិមនុស្សនៅឃុំអង្គកែវបានបញ្ជាក់ថាប្រជាពលរដ្ឋនៅឃុំអង្គកែវ នៅតែផ្តល់ការគាំទ្រស្រលាញ់គណបក្សសិទ្ធិមនុស្ស ពីព្រោះគណបក្សនោះមានគោលការណ៍ជួយអ្នកក្រឱ្យមានជីវភាពធូរធារ ជួយចាស់ជរាឱ្យមានប្រាក់ឧបត្ថម្ភ និងពិនិត្យព្យាបាលសុខភាពប្រជាពលរដ្ឋមិនបង់ប្រាក់ ។

## ឯកឧត្តម កឹម សុខា អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាមចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋនៅមូលដ្ឋាន

លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្សដែលលោកបានថ្លែងទៅកាន់សកម្មជន និងអ្នកគាំទ្រគណបក្សសិទ្ធិមនុស្សក្នុងពិធីសំណេះសំណាលថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០៩ នៅភូមិមាយមួយ ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ លោក **កឹម សុខា** បានថ្លែងបន្តទៀតថា គណបក្សកាន់អំណាចធ្វើការតាមដានគេ ការកាន់អំណាចតែម្នាក់ និងមិនយកច្បាប់ជាធំនេះជារបបកុម្មុយនីស្ត ។ ការបែងចែកប្រជាពលរដ្ឋ បក្សកាន់អំណាច បក្សប្រឆាំងហើយនៅពេលដែលអ្នកគាំទ្រគណបក្សប្រឆាំងទៅពឹងពាក់គណបក្សប្រជាជនកម្ពុជា គឺគេឱ្យទៅរកគណបក្សប្រឆាំងទង្វើបែបនេះត្រូវបាន លោក **កឹម សុខា** ចាត់ទុកថាជារបៀបដឹកនាំបែបកុម្មុយនីស្ត ។

លោក **កឹម សុខា** អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម មានប្រសាសន៍ទៀតថា នៅឆ្នាំ១៩៩៨ ឆ្នាំ២០០៣ និងឆ្នាំ ២០០៨ គណបក្សកាន់អំណាចថា អ្នករៀបចំបោះឆ្នោតគឺគណបក្ស នេះឈ្នះកាន់តែច្រើនឡើងៗ ។ ប៉ុន្តែការឈ្នះនេះមិនមែន ឈ្នះដោយបេះដូងប្រជាពលរដ្ឋពិតប្រាកដនោះទេ ។ ឈ្នះនោះ គឺឈ្នះដោយសារ សារុង បីចេង អង្ករ និងការគំរាមកំហែង បំភិតបំភ័យប្រជាពលរដ្ឋ ។

## សេចក្តីជូនដំណឹង

អគ្គលេខាធិការដ្ឋានគណបក្សសិទ្ធិមនុស្ស សូមជម្រាប ជូនដំណឹងដល់ថ្នាក់ដឹកនាំខេត្ត រាជធានី ទូទាំងប្រទេសទាំងអស់ ឱ្យបានជ្រាបថា យោងតាមគំរោងសកម្មភាពរបស់គណបក្ស សិទ្ធិមនុស្សឆ្នាំ២០០៩នេះ គណបក្សសិទ្ធិមនុស្សនឹងរៀបចំកម្ម វិធីសិក្ខាសាលាសម្រាប់ថ្នាក់ដឹកនាំខេត្ត រាជធានី នៅថ្ងៃទី២២ ២៣ ២៤ ខែឧសភា ឆ្នាំ២០០៩នេះនៅទីស្នាក់ការកណ្តាលរាជ ធានីភ្នំពេញ ។

កម្មវិធីសិក្សារួមមាន ៖

- ថ្ងៃទី១ ៖ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ ជួបជុំនៅ ទីស្នាក់ការកណ្តាលគណបក្សសិទ្ធិមនុស្សរាជធានីភ្នំពេញនៅ ម៉ោង១៤រសៀល និងម៉ោង៦:០០– ៨:០០ ពិភាក្សានយោបាយ
- ថ្ងៃទី២ ៖ ម៉ោងសិក្សាសំរាប់ថ្ងៃទី២៣ ខែឧសភា
  - ព្រឹក ៨:០០ - ១១:៣០ ផ្នែករដ្ឋបាល
  - រសៀល ១:៣០ - ៥:០០ ផ្នែកគ្រប់គ្រង
  - ល្ងាច ៦:៣០ - ៨:០០ ពិភាក្សានយោបាយ
- ថ្ងៃទី៣ ៖ ម៉ោងសិក្សាសំរាប់ថ្ងៃទី២៤ ខែឧសភា
  - ព្រឹក៨:០០ - ១១:៣០ ផ្នែកប្រាស្រ័យទាក់ទង
  - រសៀល១:៣០ - ៥:០០ ផ្នែកវិទ្យាសាស្ត្រនយោបាយ
  - ល្ងាច ៦:៣០ - ៨:០០ ពិភាក្សានយោបាយ
- ថ្ងៃទី២៥ ខែឧសភា ថ្នាក់ដឹកនាំខេត្តចេញដំណើរត្រឡប់ ទៅតាមមូលដ្ឋាន ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមថ្នាក់ដឹកនាំខេត្ត រាជធានី តាមការអញ្ជើញចូលរួម និងជ្រាបជាពតិមាន ។

| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| លោក | ម៉ី សាន | ទូរស័ព្ទលេខ: ០១១ ៩០៤ ០៣១ |
| កញ្ញា | គង់ វណ្ណា | ទូរស័ព្ទលេខ: ០១២ ៨៦៥ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |

**គោលនយោបាយគណបក្សសិទ្ធិមនុស្សបើកទូលាយក្លូវការបណ្តុះបណ្តាលសមត្ថភាពយុវជន !**